ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប

លេខ: ៧៤៨/១៦រសល

សៀមរាប ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៦

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ ២០១៧**

**រដ្ឋបាលខេត្តសៀមរាប** នឹងរៀបចំបញ្ជីអ្នកទទួលការឆ្នាំ ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ/សង្កាត់ និងគម្រោងក្រុង/ស្រុក ឆ្នាំ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោង មូលនិធិឃុំ សង្កាត់ និងគម្រោង ក្រុង/ស្រុក ទាំងអស់នៅទូទាំងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ... ។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវថ្នល់ ផ្លូវក្រួសក្រហម ... ។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប ... ។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងជាក់ស្តែង នឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច ០២ គម្រោងក្នុងរយៈពេលបីឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យផ្ទាល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាព បច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូន**អភិបាលខេត្ត** ដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថា បានពាក់ព័ន្ធនឹងការឃុបឃិតសុំគ្រប់គ្នា ការក្លែងបន្លំ និងអំពើពុករលួយ នឹងត្រូវបានដកសិទ្ធិជាប់ការជាអ្នកទទួលការ ហើយក៏នឹងមិនត្រូវបានពិចារណា បញ្ចូលឈ្មោះទៅក្នុងបញ្ជីអ្នកទទួលការសម្រាប់ឆ្នាំ ២០១៧ទៀត ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមអញ្ជើញមកដាក់ពាក្យសុំចុះ ឈ្មោះក្នុងបញ្ជីអ្នកទទួលការនៅ **ទីចាត់ការផែនការ និងវិនិយោគ នៃសាលាខេត្តសៀមរាប** ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ វេលាម៉ោង ៥ :០០ នាទី ល្ងាច**។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីនាឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការជាថ្មីម្តងទៀតដែរ ។

អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការនៅ**ទីចាត់ការផែនការ និងវិនិយោគ** ដោយឥតបង់ថ្លៃតាមរយៈអាសយដ្ឋាន **ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប** ឬអាចទាញយកពីក្នុងគេហទំព័ររបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកទទួលការទាំងអស់ជ្រាបជាព័ត៌មាន ។

**អភិបាលខេត្ត**

**ឃឹម_ប៊ុនសុង**